# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីប្រធានបទថា ការអុជធូបរបស់ពុទ្ធបរិស័ទខ្មែរ ធ្វើសក្ការបូជាចំពោះព្រះពុទ្ធមានផលមិនល្អ ដល់សុខភាពមនុស្ស ។

website: www.hoksavann.org

ថ្ងៃទី១៤ កញ្ញា ២០០៦

ក្នុងធម៌នមស្សការដែលពុទ្ធបរិស័ទខ្មែរតែងសូត្រជាដំបូងថា ឥមេហិ ទីបធូបាទីសក្កាវេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ ដែលប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានទៀននិងធូបជាដើមនេះ ។ល។ អត្ថបទនេះ ពុំមែនជាពាក្យរបស់ព្រះពុទ្ធសំដែងទេ គឺជាពាក្យរបស់អ្នកប្រាជ្ញព្រះពុទ្ធសាសនាខ្មែរតែងសម័យក្រោយ ប៉ុន្តែពុំអាចស្រាវជ្រាវឃើញឈ្មោះឬក្រុមអ្នកតែងអត្ថបទនេះទេ ។ នៅសម័យពុទ្ធកាល ពុំឃើញមានប្រើពាក្យធូបទេ តែមានប្រើពាក្យប្រទីប (ពន្លឺ) និងបុប្ផ (ផ្កា) គឺគេបូជាចំពោះព្រះរតនត្រ័យមានព្រះពុទ្ធជាដើម ដោយពន្លឺនៃទៀននិងផ្កា ឬដោយគ្រឿងក្រអូបផ្សេងៗ ដូចជាគន្ធកុដិដែលព្រះពុទ្ធគង់នៅវត្តជេតពន នាងវិសាខាតែងដាក់គ្រឿងក្រអូបក្នុងកុដិព្រះអង្គ ដូច្នេះហើយបានជាមហាជនតែហៅកុដិព្រះអង្គថា គន្ធកុដិប្រែថាកុដិក្លិន គឺកុដិមានក្លិនក្រអូប ។ ពាក្យធូបនេះចេញពីភាសាបាលី ប្រែថាផ្សែង ទំនងជាទាក់ទងនិងសាសនាព្រាហ្មណ៍ ។ តាមសាសនាព្រាហ្មណ៍ ដើម្បីឲ្យព្រះឥន្ទព្រះព្រហ្មប្រទានពរឲ្យពួកគេបានសុខ គេតែងបូជាយញ្ញមានចាប់សត្វដុតទាំងរស់ មានពេលខ្លះចាប់មនុស្សដុតទាំងរស់ថែមទៀត ។ ឯទូតដែលឲ្យដំណឹងទៅព្រះឥន្ទនិងព្រះព្រហ្មថាខ្លួន (ពួកព្រាហ្មណ៍) បូជានោះ គឺផ្សែង(ធូប) នេះឯង ។ ដូច្នេះធូបនេះ ចេញពីសាសនាព្រាហ្មណ៍ ដែលប្រែថាផ្សែង គឺផ្សែងចេញពីការបូជាយញ្ញ ហុយឡើងទៅលើជាទូតឲ្យដំណឹងទៅព្រះអាទិទេពរបស់គេ ពុំមែនជាធូបរបស់ខ្មែរធ្វើដូចសព្វថ្ងៃនេះទេ ។ នៅប្រទេសភូមា ប្រទេសសេរីលង្កា ប្រទេសនេប៉ាល់ ដែលកាន់ព្រះពុទ្ធសាសនាដូចខ្មែរ គេមិនប្រើធូបពេលធ្វើសក្ការបូជាចំពោះព្រះរតនត្រ័យទេ គឺគេប្រើទៀននិងផ្កា ។

ការប្រើធូប ក្រៅពីប្រទេសកម្ពុជា មានប្រទេសថៃនិងប្រទេសលាវ ប្រើធូបដូចប្រទេសខ្មែរដែរ ។

ការអុជធូបបូជាព្រះរតនត្រ័យតាមទម្លាប់ពុទ្ធសាសនិកជនខ្មែរ ហុចផលអាក្រក់ណាស់ដល់សុខភាពមនុស្សពេលដែលដកស្រូបក្លិនធូប ព្រោះផ្សែងធូបមានជាតិពុល ដោយផ្សែងកាត់យកខ្យល់អុកស៊ីសែនដែលបញ្ចូលឈាមឲ្យថ្លាស្អាត បំបាត់ជាតិពុលតាមរយៈការដកដង្ហើម ។ ផលវិបាកអាក្រក់ម្យ៉ាងទៀត បើដុតធូបក្នុងកុដិក្នុងសាលាក្នុងព្រះវិហារ នាំឲ្យខ្មៅត្រង់កន្លែងបរិវេណកន្លែងដែលដុតនោះ ដោយសារផ្សែងហុយទៅប៉ះជិតជាប់ ។ ការដុតធូបមានន័យថា ការបូជាផ្សែងដល់ព្រះពុទ្ធជាម្ចាស់ តើមានប្រយោជន៍អ្វីក្នុងការបូជាផ្សែងដែលជាគ្រឿងពុលនេះដល់ព្រះពុទ្ធ ។ បើព្រះពុទ្ធគង់ព្រះជន្មនៅ ហើយគេដុតធូបបូជានៅចំពោះព្រះភ័ក្ត្រ តើព្រះអង្គសព្វព្រះទ័យឬទេ នៅពេលដែលព្រះអង្គស្រូបយកផ្សែងជាតិពុលនេះ ។ ព្រះពុទ្ធនឹងហាមឃាត់ពុទ្ធបរិស័ទមិនឲ្យប្រព្រឹត្តធ្វើគ្រឿងបូជាខុសក្បួនអនាម័យបែបនេះពុំខាន ។ ព្រះពុទ្ធសំដែងថា ការធ្វើសក្ការបូជាចំពោះព្រះរតនត្រ័យដោយចិត្តជ្រះថ្លា ថាបានផលបានអនិសង្សហើយ ប៉ុន្តែចំពោះគ្រឿងសក្ការបូជាដែលមិនប៉ះពាល់ដល់សុខភាព គឺមិននាំឲ្យមានជម្ងឺ ។ បើបូជាចំពោះវត្ថុដូចជាផ្សែងធូបនេះ នាំឲ្យមានជម្ងឺ មិនត្រឹមតែមិនអនិសង្សទេ ថែមទាំងទទួលបាបថែមទៀត ព្រោះនាំឲ្យវិលមុខនៃអ្នកទៅរួមបុណ្យដោយសារស្រូបយកផ្សែងធូប ។

ការបូជាដែលបានផលបានអនិសង្សច្រើន គឺបតិបត្តិបូជា ប្រែថា ការបូជាដោយប្រតិបត្តិតាមសីលសមាធិបញ្ញា ប្រសើរជាងការធ្វើសក្ការបូជាដោយគ្រឿងសក្ការបូជាទាំងឡាយ មានបូជាផ្កាជាដើម ។ បើនៅតែចង់បូជានូវគ្រឿងសក្ការបូជា គួរដកយកធូបចេញកុំបូជា គួរបូជាតែផ្កាឬពន្លឺដូចដុតទៀនជាដើមបានហើយ ។ ក្នុងន័យនេះ បើនៅតែចង់សូត្រធម៌ ឥមេហិ នេះ គួរដកពាក្យថា ធូបា ចេញ ហើយបញ្ចូលពាក្យបុប្ផវិញ គឺបញ្ចូលថា ឥមេហិ ទីបបុប្ផ ទីសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ ប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការបូជាទាំងឡាយមានទៀននិងផ្កាជាដើមនេះ ។ ត្រង់នេះគេអាចកែបាន ព្រោះមិនមានជាពាក្យព្រះពុទ្ធដីកា ជាពាក្យរបស់ខ្មែរ ចងក្រងជំនាន់ក្រោយ ព្រោះសូម្បីតែថៃនិងលាវ ដែលប្រើការអុជធូបដែរនោះ ពុំមានអម៌ឥមេហិនេះទេ ។ សូមកុំយល់ថា ទម្លាប់ដែលធ្លាប់ធ្វើមកហើយ បើមិនធ្វើនាំឲ្យមានទោសនោះឡើយ ។ ទម្លាប់ខ្លះ គេអាចកែបានបើទម្លាប់នោះមិនល្អ ដោយកែទៅរកទម្លាប់ល្អ ឆ្ពោះទៅរកការជឿនលឿន ដូចធម៌ចាស់ធម៌ថ្មី គឺធម៌ចាស់ជាធម៌មិនបកប្រែ នៅសូត្រជាភាសាបាលី ឯធម៌ថ្មីគឺបកប្រែឲ្យស្តាប់សេចក្តីបាន វៀរលែងតែពាក្យព្រះពុទ្ធដីកា ដែលគេពុំអាចកែប្រែបាន ។ បើថ្វាយបង្គំមិនបាន អុជទៀនឬបូជាផ្កា ក៏មិនមានទាស់ខុសអ្វីឡើយ គ្មានព្រះវិន័យណាចែងថា ថ្វាយបង្គំត្រូវតែអុជទៀនធូប ឬបូជាផ្កាឡើយ បើ

មានក៏បូជាទៅ ។ ការថ្វាយបង្គំនេះ មានន័យជាពិសេសគឺនឹកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនេះឯង ។ មានអ្នកខ្លះថា បើសូត្រ ឥមេហិ មិនបានអុជទៀនជាដើមទេ មិនហ៊ានសូត្រទេ ព្រោះកុហកព្រះ ។ យល់ដូច្នេះក៏ត្រូវមិនសូត្រក៏បាន ប៉ុន្តែបើទម្លាប់សូត្រទៅហើយ បើសូត្រទៅដោយតាំងចិត្តថា ទៀនផ្កានៅក្នុងចិត្តក៏គ្មានទាស់ខុសអ្វីដែរ ព្រោះបើមិនសូត្រឥមេហិ សូត្រសង្ខេប ក៏មានពាក្យថ្វាយគ្រឿងសក្ការបូជានៅក្នុងនោះដែរ ។

ពេលភ្ជុំបិណ្ឌ ពេលចូលឆ្នាំ ពុទ្ធបរិស័ទអុជធូបហុយទ្រលោម សំបូងសំរូងប្រតិស្ឋអធិដ្ឋានសុំសេចក្ដីសុខនិងឧទ្ទិសកុសលដល់មាតាបិតាជីដូនជីតាញាតិកា៧សន្តាន ។ ចុះបើមិនអុជធូបសំបូងសំរូង មិនកើតឬ ? តាមពិតការអធិដ្ឋានចិត្ត ពុំមែនស្ថិតនៅលើធូបទេ គឺស្ថិតនៅលើផ្លូវចិត្តទៅវិញទេ ។ ផលវិបាកអាក្រក់មួយទៀត ការអុជទៀនធូបដោយភ្លេចពន្លត់ ខ្យល់បក់មក ឬរលំទៅឆេះរបស់របរផ្សេងៗ រហូតខ្លះមានឆេះផ្ទះទៀតផង ។ តាមសេចក្ដីដូចបានពោលមកហើយនេះ គួរអ្នកទទួលខុសត្រូវខាងព្រះពុទ្ធសាសនា និងពុទ្ធបរិស័ទខ្មែរទូទៅយកទៅពិចារណា គួរឈប់ប្រើធូបក្នុងការធ្វើសក្ការបូជាចំពោះព្រះរតនត្រ័យ ដោយកែធម៌ឥមេហិ ត្រង់ធូបាមកជាបុប្ផាវិញ គឺបូជាព្រះទីបមានភ្លើងទៀនជាដើមនិងផ្កា គ្រឿងក្រអូបជាដើមវិញដើម្បីអនាម័យ ដូចប្រទេសភូមា ប្រទេសស្រីលង្កាជាដើម គេប្រើតែទៀននិងផ្កា គេមិនប្រើធូបឡើយ ។ ទោះបីពុទ្ធបរិស័ទអុជធូបទៀននៅខាងក្រៅកុដិសាលាវិហារក៏ដោយ ក៏ពុំឃើញមានប្រយោជន៍ ដែលកើតអំពីការអុជធូបនេះឡើយ ឃើញតែចំណាយថវិកាក្នុងការជាវធូបមកអុជអស់ប្រាក់កាសប៉ុណ្ណោះ ។៚

❑ ❑

❑